ប្រព័ន្ធអាវុធស្វយ័តដ៏ក្រោះថ្នាក់ៈ ជំហានបឋមសម្រាប់គោលនយោបាយ របស់ប្រទេសកម្ពុជា

អង្គការអហិង្សាអន្តរជាតិអាស៊ីអាគ្នេយ៍

អង្គការយុវសន្តិភាព

ខែមករា ឆ្នាំ២០២១

©ខែមករា ឆ្នាំ២០២១

អង្គការអហិង្សាអន្តរជាតិអាស៊ីអាគ្នេយ៍
អង្គការយុវសន្តិភាព

សេចក្តីថ្លែងអំណរគុណ

ការបោះពុម្ពផ្សាយសៀវភៅនេះអាចធ្វើទៅបានដោយមានការគាំទ្រថវិកាពីយុទ្ធនាការជាសកលដើម្បីបញ្ឈប់មនុស្សយន្តពិឃាដ។
អង្គការអហិង្សាអន្តរជាតិអាស៊ីអាគ្នេយ៍ សូមថ្លែងអំណរគុណដល់អង្គការយុវសន្តិភាពដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់ពួកគេ ក្នុងការផ្តល់ឯកសារ និងធាតុចូលពាក់ព័ន្ធជាច្រើនសម្រាប់ការបកប្រែ ដែលសម្របទៅនឹងបរិបទកម្ពុជា។
អង្គការអហិង្សាអន្តរជាតិអាស៊ីអាគ្នេយ៍ និងអង្គការយុវសន្តិភាពសង្ឃឹមថាសៀវភៅនេះនឹងចូលរួមចំណែកដល់ការយល់ដឹងអំពីអាវុធបញ្ញាសិប្បនិមិត្ត (AI) និងអាវុធស្វយ័តពេញលេញ និងលើកទឹកចិត្តឱ្យអង្គការកាន់តែច្រើនទៀតចូលរួមក្នុងយុទ្ធនាការជាសកលដើម្បីបញ្ឈប់មនុស្សយន្តពិឃាដ។
អង្គការអហិង្សាអន្តរជាតិអាស៊ីអាគ្នេយ៍ និងអង្គការយុវសន្តិភាពសូមថ្លែងអំណរគុណដល់លោក ម៉ន សុគឿន អ្នកនាងជេដ្ឋា រចនា និងកញ្ញា ជ្រុន ហេងកនិកា ដែលបានជួយក្នុងដំណើរការបកប្រែ។ ■

អក្សរកាត់

AI	បញ្ញាសិប្បនិមិត្ត (Artificial intelligence)
ATT	សន្ធិសញ្ញាពាណិជ្ជកម្មអាវុធ (Arms Trade Treaty)
AWS	ប្រព័ន្ធអាវុធស្វយ័ត (Autonomous weapons system)
Bafa	ការិយាល័យសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចការសេដ្ឋកិច្ច និងការត្រួតពិនិត្យការនាំចេញ (German Federal Office for Economic Affairs and Export Control (Bafa)
CCM	អនុសញ្ញាស្តីពីគ្រាប់បែកចង្កោម (Convention on Cluster Munitions)
CCW	អនុសញ្ញាស្តីពីអាវុធធម្មតាមួយចំនួន (Convention on Certain Conventional Weapons)
CSKR	យុទ្ធនាការដើម្បីបញ្ឈប់មនុស្សយន្តពិឃាដ (Campaign to Stop Killer Robots)
CSO	អង្គការសង្គមស៊ីវិល (Civil society organization)
DMZ	តំបន់គ្មានយោធា (Demilitarized zone)
IHL	ច្បាប់មនុស្សធម៌អន្តរជាតិ (International humanitarian law)
OPCW	អង្គការហាមឃាត់អាវុធសារធាតុគីមី (Organization for the Prohibition of Chemical Weapons)
LAWS	ប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (Lethal autonomous weapons systems)
LOAC	ច្បាប់ជម្លោះប្រដាប់អាវុធ (Laws of armed conflict)
NISEA	អង្គការអហិង្សាអន្តរជាតិអាស៊ីអាគ្នេយ៍ (Nonviolence International Southeast Asia)
PLA	កងទ័ពរំដោះប្រជាជន (People's Liberation Army)
UAV	យានអវកាសគ្មានមនុស្សបើក (Unmanned aerial vehicle)
UGV	យានលើដីគ្មានមនុស្សបើក (Unmanned ground vehicle)

មាតិកា

សេចក្តីថ្លែងអំណរគុណ	**3**
អក្សរកាត់	**4**
មាតិកា	**5**
បុព្វកថា	**6**
ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់: មូលដ្ឋានគ្រឹះ	**7**
តើអ្វីទៅជាប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់?	7
តើប្រទេសផ្សេងទៀតឲ្យនិយមន័យប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់នេះយ៉ាងដូចម្តេច?	8
តើស្វ័យភាពកម្រិតណា ត្រូវបានគេចាត់ទុកថា "ស្វយ័ត" នៅក្នុងម៉ាស៊ីន?	9
តើបញ្ញាកម្រិតណា ត្រូវបានគេចាត់ទុកថា “ឆ្លាតវៃ” នៅក្នុងម៉ាស៊ីន?	10
ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់: បញ្ហាសកល	**13**
ហេតុអ្វីបានជាប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់គឺ ជាបញ្ហាសកល?	13
តើមានអំណះអំណាងអ្វីខ្លះដែលយល់ស្របឲ្យមានប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់?	14
តើមានអំណះអំណាងអ្វីខ្លះដែលប្រឆាំងនឹងប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់?	15
តើប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ជះឥទ្ធិពលអ្វីខ្លះដល់ច្បាប់មនុស្សធម៌?	16
តើប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់រំលោភសិទ្ធិមនុស្សដែរឬទេ?	16
តើស្ត្រីទទួលរងផលប៉ះពាល់យ៉ាងដូចម្តេចពីការរីកសាយនៃប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់?	17
ប្រសិនបើប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ត្រូវបានប្រើប្រាស់ តើនរណាជាអ្នកទទួលខុសត្រូវ?	17
តើប្រទេសណាខ្លះបានកំពុងតែផលិតប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់រួចទៅហើយ?	17
តើកិច្ចពិភាក្សាក្នុងអនុសញ្ញាស្តីពីអាវុធធម្មតាមួយចំនួនស្តីអំពីបញ្ហាប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ដំណើរការដល់ណា?	19
តើច្បាប់អន្តរជាតិអ្វីខ្លះពាក់ព័ន្ធនឹងប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់?	20
ប្រទេសកម្ពុជា និងប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់	**21**
តើច្បាប់ជាតិរបស់ ប្រទេសកម្ពុជា ដែលទាក់ទងនឹងប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់មានអ្វីខ្លះ?	21
ហេតុអ្វីបានជា ប្រទេសកម្ពុជា គួរគាំទ្រឲ្យមានការចរចារលើសន្ធិសញ្ញាថ្មីមួយស្តីពីប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់?	22
ហេតុអ្វីប្រទេសកម្ពុជាគួរគាំទ្រការហាមឃាត់ប្រព័ន្ធអាវុធស្វ័យភាពដ៏គ្រោះថ្នាក់?	23
កិច្ចខិតខំប្រឹងប្រែងរបស់សង្គមស៊ីវិល	**24**
ហេតុអ្វីប្រទេសកម្ពុជាគួរគាំទ្រការហាមឃាត់ប្រព័ន្ធអាវុធស្វ័យភាពដ៏គ្រោះថ្នាក់?	24

បុព្វកថា

ការស្រាវជ្រាវ និងការអភិវឌ្ឍប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) គឺស្ថិតនៅក្នុងដំណាក់កាលចាប់ផ្តើម ដែលភាគច្រើនត្រូវបានជម្រុញដោយបណ្តាប្រទេសអភិវឌ្ឍន៍ ដើម្បីពង្រីកសមត្ថភាពវិស័យយោធារបស់ខ្លួន។ ទោះបីវាស្ថិតក្នុងដំណាក់កាលផ្តើមក៏ដោយ ក៏ប៉ុន្តែបច្ចេកវិទ្យា ដែលត្រូវបានប្រើប្រាស់សម្រាប់ផលិតជាផ្នែក និងជាបណ្តុំ គឺមានរួចរាល់ហើយ។ លក្ខណៈចម្បងនៃប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) គឺស្វ័យភាពក្នុងការជ្រើសរើសយកមុខងារសកម្មភាព និងភាពវៃឆ្លាត ដើម្បីធ្វើប្រតិបត្តិការតាមដែលវាចង់ធ្វើ។ ស្វ័យភាព និងបញ្ញា គឺជាលក្ខណៈសំខាន់របស់វា។ ដើម្បីឱ្យម៉ាស៊ីនធ្វើសកម្មភាពដោយស្វ័យប្រវត្តិ និងឈ្លាសវៃ នោះបញ្ញាសិប្បនិម្មិត(AI) ឬបញ្ញារបស់ម៉ាស៊ីនត្រូវតែមានភាពទំនើប។

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ កំណើននៃការស្រាវជ្រាវ និងការអភិវឌ្ឍរបស់បញ្ញាសិប្បនិម្មិត(AI) មានដំណើរការស្របគ្នាទៅតាមការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហូបនីយកម្មបានយ៉ាងឆាប់រហ័ស។ ម៉ាស៊ីនដែលមានភាពវៃឆ្លាតខុសគ្នា។ ត្រូវបានគេប្រើប្រាស់ក្នុងការងារជាមូលដ្ឋានរបស់មនុស្សជាតិក្នុងវិស័យវេជ្ជសាស្ត្រ ការដឹកជញ្ជូន ភស្តុភារនិងសូម្បីតែការកំសាន្ត។ បញ្ញាសិប្បនិម្មិត (AI) ដំបូងបង្អស់ដែលត្រូវបានគេផលិតឡើង ដើម្បីលេងអុកនៅឆ្នាំ១៩៩៧ដែលមានឈ្មោះថា ឌីបប្ល (Deep Blue) គឺប្រហែលជាបុព្វបុរសរបស់ហ្គូហ្គោលឌីបម៉ាញ (Google Deep Mind) នៅសតវត្សរ៍ទី២១ ដែលបានផ្ទួលជើងឯកពិភពលោក លីសេដុល ក្នុងឆ្នាំ២០១៦[1] ។ នៅពេលត្រូវបានគេប្រើប្រាស់ ក្នុងឧស្សាហកម្ម បញ្ញាសិប្បនិម្មិត (AI) បានក្លាយជាឧបករណ៍ដ៏ល្អនៃវឌ្ឍនភាព ហើយនៅពេលដែលត្រូវបានគេប្រើទៅលើសញ្ញាវុធ បញ្ញាសិប្បនិម្មិត(AI) វាអាចជួយសង្គ្រោះជីវិត ឬក៏ផ្តល់នូវគ្រោះថ្នាក់ដល់ជីវិតមនុស្សបានដូចគ្នា។ ការប្រើប្រាស់បញ្ញាសិប្បនិម្មិត(AI) នៅក្នុងប្រព័ន្ធសញ្ញាវុធ និងបច្ចេកវិទ្យាដែលកំពុងលេចធ្លោដទៃទៀត បានក្លាយជាប្រធានបទនៃវិវាទក្នុងអំឡុងប៉ុន្មានឆ្នាំថ្មីៗនេះដោយសារតែសក្តានុពលរបស់វាត្រូវបានគេប្រើប្រាស់ដោយមិនត្រឹមត្រូវ។

ជំហានបឋមនេះ នឹងធ្វើការពន្យល់ពីការវិវឌ្ឍន៍ថ្មីៗជុំវិញប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) និងបច្ចេកវិទ្យាដែលកំពុងលេចធ្លោដទៃទៀត ក្នុងវិស័យអភិវឌ្ឍសញ្ញាវុធ។ វាគួរតែត្រូវបានចាប់ផ្តើមដោយនិយមន័យនៃប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) និងតម្រូវការបញ្ញាសិប្បនិម្មិត (AI) របស់វា។ ជំហានបឋមនឹងពិនិត្យមើលដោយសង្ខេបអំពីការអភិវឌ្ឍប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់(LAWS)នៅក្នុងប្រទេសអាស៊ីមួយចំនួន និងពិភាក្សាអំពីឆន្ទៈរបស់ពួកគេក្នុងការអនុវត្តវា។ វាគួរតែមានភ្ជាប់ជាមួយនឹងអំណះអំណាងដែលស្រប នឹងការប្រឆាំងស្តីពីការបង្កើតប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS)។ គួរតែពិនិត្យមើលផងដែរថា តើប្រទេសកម្ពុជាមានច្បាប់ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ និងការប្រើប្រាស់ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) នេះបានកម្រិតណា? ជាចុងក្រោយ ឯកសារនេះនឹងបង្ហាញអំពីភាពផ្សេងគ្នានៃក្រមសីលធម៌ និងសីលធម៌ផ្សេងៗ ដែលទាក់ទងនឹងការរីកសាយនៃប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS)។

នៅពេលលើកឡើងអំពីប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) ក្នុងជំហានបឋមនេះ គឺពាក់ព័ន្ធនឹងប្រព័ន្ធអាវុធស្វយ័តដែលមានភាពពេញលេញ វាមិនត្រឹមតែប្រព័ន្ធអាវុធស្វ័យប្រវត្តិ និងស្វ័យប្រវត្តិកម្មប៉ុណ្ណោះទេ។ ពេលខ្លះ ពាក្យប្រព័ន្ធអាវុធស្វយ័ត(AWS)នឹងត្រូវបានប្រើដើម្បីសំដៅទៅលើប្រព័ន្ធអាវុធពាក់កណ្តាលស្វយ័ត ឬស្វយ័តពេញលេញ ដែលអាចបង្កអន្តរាយដោយមិនរាប់បញ្ចូលពីភាពគ្រោះថ្នាក់របស់វា។ ■

1 Salder, M. & Regan, N. (2019, February 3). DeepMind's superhuman AI is rewriting how we play chess. Wired. Retrieved from https://www.wired.co.uk/article/deepmind-ai-chess.

ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់: មូលដ្ឋានគ្រឹះ

តើអ្វីទៅជាប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់?

"អាវុធដែលអាចជ្រើសរើស និងកំណត់គោលដៅដោយគ្មានការអន្តរាគមន៍ពីមនុស្ស"

យ៉ាងហោចណាស់ ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ត្រូវបានគេឱ្យនិយមន័យថាជា" អាវុធដែលអាចជ្រើសរើស និងកំណត់គោលដៅដោយគ្មានការអន្តរាគមន៍ពីមនុស្ស"[2]។ ប្រព័ន្ធអាវុធស្វយ័តពេញលេញមានសមត្ថភាពក្នុងការកំណត់ភាពគ្រោះថ្នាក់របស់វា ដោយសម្គាល់វាចេញពីគោលដៅសក្តានុពលជាច្រើន និងចាត់វិធានការដើម្បីស្វែងរក និងពាក់ព័ន្ធដល់គោលដៅនោះ។

ប្រព័ន្ធអាវុធស្វយ័ត និងវៃឆ្លាតពេញលេញដែលអាចកំណត់គោលដៅ និងតាមរកមនុស្ស គឺស្ថិតនៅមិនឆ្ងាយពីការរំពឹងទុកឡើយ។ អាវុធស្វយ័តដែលមានស្រាប់ ដូចជាគ្រាប់បែកផ្លោងដែលត្រូវបានពង្រាយដើម្បីបំផ្លាញប្រព័ន្ធវ៉ាដា និងប្រព័ន្ធការពារអាកាសរបស់សត្រូវ មានសមត្ថភាពក្នុងការស្វែងរក និងកម្ទេចគោលដៅរបស់ខ្លួនដោយឯករាជ្យរួចទៅហើយ។ អាយអេអាយ ហាពី (IAI Harpy) និងអាយអេអាយ ហារ៉ុប (IAI Harop) គឺជាឧទាហរណ៍នៃឧបករណ៍បំផ្ទុះទាំងនោះ។ សូម្បីតែអាវុធស្វយ័តពាក់កណ្តាលក៏អាចត្រូវបានគេអភិវឌ្ឍទៅជាប្រព័ន្ធស្វយ័តពេញលេញមួយផងដែរ។ បច្ចេកវិទ្យា និងមធ្យោបាយមានរួចទៅហើយ ដូច្នេះមានតែរង់ចាំពេលវេលាមកដល់ មុនពេលដែលប្រព័ន្ធអាវុធស្វយ័តពេញលេញអាចកំណត់គោលដៅទៅកាន់មនុស្សបាន។ លើសពីនេះទៀត ភាពគ្រោះថ្នាក់របស់វាមិនមែនត្រឹមតែជាការព្រួយបារម្ភតែមួយគត់ទាក់ទងនឹងម៉ាស៊ីនទាំងនេះទេ។ ប្រព័ន្ធអាវុធស្វយ័តមិនចាំបាច់ទាល់តែបង្ក្រគ្រោះថ្នាក់ទើបអាចដាក់ប្រើប្រាស់ជាអាវុធ ឬដាក់ពង្រាយប្រឆាំងនឹងមនុស្សជាតិឡើយ។

ការស្រាវជ្រាវ និងការអភិវឌ្ឍនៅតែកំពុងបន្ត។ ដូចនេះហើយ ទើនមិនទាន់មាននិយមន័យ ដែលបានឯកភាពជាសកលលើប្រព័ន្ធអាវុធស្វយ័ភាពគ្រោះថ្នាក់នេះនៅឡើយទេ។ ទោះជាយ៉ាងណា អ្នកជំនាញយល់ស្របថា ទាំងស្វយ័ភាព និងភាពវៃឆ្លាត គឺចាំបាច់ណាស់ដើម្បីអនុវត្តមុខងារឯករាជ្យ ដូចជាការជ្រើសរើសគោលដៅ និងការវិនិច្ឆ័យតម្រូវការដើម្បីកម្ទេចគោលដៅនោះ។ ■

2 Ekelhof, M. & Struyk, M. (2014). Deadly decisions: 8 objections to killer robots. Utrecht: PAX, p. 4. Retrieved from https://www.paxforpeace.nl/media/files/deadlydecisionsweb.pdf.

តើប្រទេសផ្សេងទៀតឱ្យនិយមន័យប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់នេះយ៉ាងដូចម្តេច?

សហរដ្ឋអាមេរិកចាត់ទុកថាជាប្រព័ន្ធអាវុធស្វយ័តប្រសិនបើវាជា ប្រព័ន្ធអាវុធមួយដែលនៅពេលចាប់ផ្តើមដំណើរការ វាអាចជ្រើសរើស និងកំណត់គោលដៅ ដោយគ្មានអន្តរាគមន៍បន្ថែមពីប្រតិបត្តិករ។ នេះរួមបញ្ចូលទាំងប្រព័ន្ធអាវុធស្វយ័តដែលត្រូវបានរចនាឡើង ត្រួតពិនិត្យ និងប្រព្រឹត្តិទៅតាមការកំណត់របស់មនុស្ស លើប្រព័ន្ធប្រតិបត្តិការ ដើម្បីអាចមានលទ្ធភាពក្នុងការងារជ្រើសរើស និងកំណត់គោលដៅដោយគ្មានការចូលរួមបន្ថែមទៀតពីមនុស្ស បន្ទាប់ពីចាប់ផ្តើមដំណើរការ[3]។ ការធ្វើអន្តរាគមន៍ពីមនុស្សក្នុងករណីនេះ គឺត្រូវបានកំណត់ដាច់ខាតចំពោះតែ **"ការបើក និងបិទ"** ប៉ុណ្ណោះ ខណៈពេលដែលម៉ាស៊ីននៅតែធ្វើសកម្មភាពឯករាជ្យដោយខ្លួនឯងនៅពេលប្រតិបត្តិការ។

ចក្រភពអង់គ្លេសមិនទាន់បានធ្វើការបញ្ជាក់ជាក់លាក់លើអាវុធស្វយ័តពេញលេញនៅឡើយទេ ប៉ុន្តែបានកំណត់នូវអ្វីដែលខ្លួនចាត់ទុកថាជាប្រព័ន្ធស្វយ័តពោលគឺ ប្រព័ន្ធមួយដែលមានសមត្ថភាពយល់ដឹងពីចេតនា និងទិសដៅកម្រិតខ្ពស់... [ឬ] មានសមត្ថភាពចាត់វិធានការសមស្របទៅនឹងស្ថានភាពដែលចង់បាន...[ឬ]សមត្ថភាពក្នុងការសម្រេចចិត្តជ្រើសធ្វើសកម្មភាពមួយក្នុងជម្រើសជាច្រើន ដោយមិនពឹងផ្អែកលើការឃ្លាំមើល ឬការត្រួតពិនិត្យរបស់មនុស្ស[4]។ ទស្សនៈនេះបង្ហាញពីភាពវៃឆ្លាតនៃប្រព័ន្ធស្វយ័ត និងភាពឯករាជ្យរបស់វាដោយមិនពឹងពាក់សកម្មភាពមនុស្ស។ ភាពវៃឆ្លាតមានន័យថា ជាការឈ្វេងយល់ពីតម្រុយបរិបទនៃទិន្នន័យ ដែលស្រង់បាន និងអាចវិភាគ **"ចេតនានិងទិសដៅកម្រិតខ្ពស់"** ដែលមានតែមនុស្សប៉ុណ្ណោះទើបអាចពិនិត្យពិចារណាបាន។ និយមន័យរបស់ចក្រភពអង់គ្លេស ក៏បានបញ្ជាក់ផងដែរថាប្រព័ន្ធផ្សេងទៀតទាំងអស់ដែលខ្វះលក្ខណៈស្តង់ដារនៃភាពវៃឆ្លាតនេះ ក៏ត្រូវបានគេចាត់ទុកថាជាម៉ាស៊ីនស្វ័យប្រវត្តិកម្ម និងមិនមែនជាម៉ាស៊ីនស្វយ័តទេ[5]។

ទន្ទឹមនេះដែរ ប្រទេសចិនបានសំដៅទៅលើ" អាវុធវៃឆ្លាត" ឬ" អាវុធបញ្ញាសិប្បនិមិត្ត" នៅក្នុងផែនការទំនើបកម្មយោធារបស់ខ្លួន[6]។ កងទ័ពរំដោះប្រជាជន (PLA) កំណត់ថា" អាវុធវៃឆ្លាត" ជា"អាវុធដែលប្រើប្រាស់ បញ្ញាសិប្បនិមិត្ត(AI)ដើម្បីស្វែងរក តាមបំបែក និងបំផ្លាញគោលដៅសត្រូវដោយស្វ័យប្រវត្តិ ដែលជារឿយៗរួមមានប្រព័ន្ធប្រមូល និងគ្រប់គ្រងព័ត៌មាន ប្រព័ន្ធមូលដ្ឋានចំណេះដឹង ប្រព័ន្ធជំនួយការសម្រេចចិត្ត ប្រព័ន្ធអនុវត្តបេសកកម្ម។ ល។[7] ជាថ្មីម្តងទៀតកម្រិតជាក់លាក់នៃភាពឆ្លាតវៃទាមទារឱ្យ មានសមត្ថភាពក្នុងការ "ស្វែងរក តាមបំបែក និងបំផ្លាញ" គោលដៅ ដែលជាទូទៅតែងមានក្នុងគោលគំនិតភាគច្រើនដែលស្តីពីប្រព័ន្ធអាវុធស្វយ័តពេញលេញ។ ■

3 Department of Defense. (2017, May 8). Directive 3000.09, autonomy in weapon systems, November 21, 2012, incorporating change 1, May 8, 2017, pp. 13-14. Retrieved from https://www.esd.whs.mil/Portals/54/Documents/DD/issuances/dodd/300009p.pdf.

4 UK Ministry of Defence. (2017). Joint doctrine publication 0-30.2: Unmanned aircraft systems, p. 72. Retrieved from https://assets.publishing.service.gov.uk/government/uploads/system/uploads/attachment_data/file/673940/doctrine_uk_uas_jdp_0_30_2.pdf.

5 Scharre, P. (2018). Army of none: Autonomous weapons and the future of war. New York: W.W. Norton.

6 Kania, E.B. (2020, April). "AI weapons" in China's military innovation. The Brookings Institution. Retrieved from https://www.brookings.edu/research/ai-weapons-in-chinas-military-innovation/.

7 全军军事术语管理委员会 [All-Military Military Terminology Management Committee]. (2011). 中国人民解放军军语 [People's Liberation Army Military Terminology], (Beijing: 军事科学出版社 [Military Science Press]). Cited in Kania, E.B. (2020, April). "AI weapons" in China's military innovation. The Brookings Institution. Retrieved from https://www.brookings.edu/research/ai-weapons-in-chinas-military-innovation/.

តើស្វ័យភាពកម្រិតណា ត្រូវបានគេចាត់ទុកថា "ស្វយ័ត" នៅក្នុងម៉ាស៊ីន?

ម៉ាស៊ីនអាចមានកម្រិតស្វ័យភាពខុសៗគ្នាអាស្រ័យនឹងភាពទាក់ទងគ្នាយ៉ាងច្របូកច្របល់នៃវត្តមាន ឬ អវត្តមាននៃបញ្ញា។ ម៉ាស៊ីនមិនអាចស្វយ័តពេញលេញទេ លុះត្រាតែវាអាចសម្រេចចិត្តលើសកម្មភាពបន្តបន្ទាប់ដោយខ្លួនឯង។ ភាពវៃឆ្លាតនោះ ឯងដែលអនុញ្ញាតឱ្យម៉ាស៊ីនធ្វើការសម្រេចចិត្តបាន។

ពាក្យថា ស្វ័យប្រវត្តិ និងស្វ័យប្រវត្តិកម្ម តែងត្រូវបានគេប្រើប្រាស់ជំនួសគ្នាជាញឹកញាប់ ប៉ុន្តែវាមានភាពខុសគ្នាបន្តិចបន្តួច។ បើប្រៀបនឹងម៉ាស៊ីនស្វយ័ត ពួកគេស្ថិតនៅកម្រិតទាបជាងនៅលើវិសាលភាពនៃម៉ាស៊ីនវៃឆ្លាត។ ■

កម្រិតផ្សេងគ្នានៃស្វ័យភាព



Automatic



Automated

Self-autonomous

Fully autonomous and intelligent

តើបញ្ហាកម្រិតណា ត្រូវបានគេចាត់ទុកថា "ឆ្លាតវៃ" នៅក្នុងម៉ាស៊ីន?

បញ្ហានៅក្នុងប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) ត្រូវបានបង្ហាញជាពីរយ៉ាងគឺ ការសម្គាល់អត្តសញ្ញាណស្វយ័ត និងការចូលរួមស្វយ័ត។

ការកំណត់អត្តសញ្ញាណហាក់ដូចជាកិច្ចការជាមូលដ្ឋានសម្រាប់មនុស្ស។ ប៉ុន្តែសម្រាប់ម៉ាស៊ីនដើម្បីអភិវឌ្ឍសមត្ថភាពនេះវាតម្រូវអោយមានការអនុវត្តក្បួនដោះស្រាយជាក់លាក់មួយ។ ជាការពិតទៅ កម្រិតនៃភាពស្មុគស្មាញរបស់វាយ៉ាងណានោះគឺត្រូវបានបង្ហាញនៅក្នុងសមត្ថភាពនៃបណ្តាញប្រព័ន្ធប្រសាទយ៉ាងជ្រៅ ដែលបានដាក់ឲ្យប្រើប្រាស់ក្នុងការរៀនតាមម៉ាស៊ីន ដូចជាហ្គូដហ្គលឌីបម៉ាញ (Google DeepMind) ដើម្បីទាញយកព័ត៌មានដ៏ច្រើនសន្ធឹកសន្ធាប់ និងការកំណត់សំណុំនៃសកម្មភាពដើម្បីសម្រេចបាននូវកម្មវត្ថុដែលបានគ្រោងទុកជាមុន។

ការបង្ហាញរបស់ហ្គូហ្គោលឌីបម៉ាញ (Google DeepMind) ជាមួយម្ចាស់ជើងឯក លី សេដុល នៅក្នុងការលេងហ្គេមស្មុគស្មាញ ហ្គោ (Go) ប្រភព៖ CNet[8]

កម្មវិធីសូហ្វវែរសម្គាល់រូបភាពបានប្រើក្បួនដោះស្រាយដែលផ្តួតផ្គងលក្ខណៈពិសេសនៃរូបភាពមួយជាមួយនឹងរូបភាពដទៃទៀតនៅក្នុងប្រព័ន្ធទិន្នន័យរបស់វា ហើយក្នុងពេលតែមួយបែងចែកពួកវាតាមរយៈដំណើរការនៃការលុប។ ដើម្បីកំណត់អត្តសញ្ញាណរូបភាពមួយឱ្យបានត្រឹមត្រូវ កម្មវិធីសូហ្វវែរត្រូវផ្តល់រាប់ពាន់រូបភាព ឬពេលខ្លះអាចដល់រាប់លានរូបភាព ដើម្បីប្រើជាឯកសារយោងនៅក្នុងការកំណត់របស់វា។

8 Reilly, C. & Lancaster, L. (2016, March 8). Google turns game of Go into massive AI-vs-human spectacle. CNet. Retrieved from https://www.cnet.com/news/google-deepmind-hooked-us-on-go-the-geekiest-game-youve-never-heard-of/.



លទ្ធផលនៃការប្រកួតប្រជែងសូហ្វវែរសម្គាល់រូបភាពរបស់ GoogleNet
ប្រភព: Google AI Blog[9]

កម្មវិធីសូហ្វវែរសម្គាល់ផ្ទៃមុខមួយចំនួន យករូបរាងតាមបែបធរណីមាត្រ ជម្រៅ និងសាច់ផ្ទៃមុខ មកគណនាដោយយោងទៅលើលក្ខណៈពិសេសទាំងនេះជាមួយរូបភាពរាប់ពាន់មុនពេលបង្កើតចេញជាលទ្ធផល។ ទោះយ៉ាងណា បច្ចេកវិទ្យាមិនមែនជាភស្តុតាងពេញលេញទេ។ បណ្តាញប្រសាទជ្រៅដែលមានសមត្ថភាពរៀនសូត្រ អាចបង្កើតការបកស្រាយរបស់ពួកគេទៅលើវត្ថុមួយចេញពីលំហាត់ផ្ទូផ្ទងរូបភាពជាច្រើន ដូចជានៅក្នុងការផ្ទូផ្ទងរូបថតរបស់សត្វជាមួយ និងរូបភាពអរូបី ឬរូបភាពមិនពិតដែលវាត្រូវបានគេចាត់ទុកថាដូចគ្នាបេះបិទ[10]។ ក៏មានរបាយការណ៍ស្តីពីកម្មវិធីសូហ្វវែរសម្គាល់ផ្ទៃមុខដែលមានអត្រាផ្ទូរផ្ទេរវិជ្ជមានខ្ពស់សម្រាប់ជនជាតិស្បែកសជាងជាតិសាសន៍ដទៃទៀត[11]



ឧទាហរណ៍នៃកម្មវិធីសូហ្វវែរសម្គាល់ផ្ទៃមុខ
ប្រភព: ទស្សនាវដ្តីសន្តិសុខ[12]

9 Szegedy, C. (2014, September 5). Building a deeper understanding of images. Google AI Blog. Retrieved from https://ai.googleblog.com/2014/09/building-deeper-understanding-of-images.html.
10 Scharre, P. (2018). Army of none: Autonomous weapons and the future of war. New York: W.W. Norton.
11 Lohr, S. (2018, February 9). Facial recognition is accurate, if you're a white guy. The New York Times. Retrieved from https://www.nytimes.com/2018/02/09/technology/facial-recognition-race-artificial-intelligence.html
12 Ushering next generation facial recognition. (2019, August 15). Security Magazine. Retrieved from https://www.securitymagazine.com/articles/90672-ushering-next-generation-facial-recognition.

ខណៈពេលដែលភាពវៃឆ្លាតអនុញ្ញាតឱ្យម៉ាស៊ីនកំណត់ភារកិច្ចបន្ទាប់របស់ខ្លួន ស្វ័យភាពអនុញ្ញាតឱ្យវាធ្វើសកម្មភាពដោយគ្មានអន្តរាគមន៍ពីមនុស្ស។ នេះមានន័យថាមនុស្សគឺ«លែងជាប់ពាក់ព័ន្ធ»នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងប្រតិបត្តិការទៀតហើយ។ ម៉ាស៊ីនស្វ័យប្រវត្តិកម្ម ឬស្វ័យប្រវត្តិ ធ្វើតាមកម្មវិធីជាក់លាក់មួយដែលកំណត់សកម្មភាពរបស់ខ្លួនពីចំណុច ក ទៅចំណុច ខ។ នៅពេលណាមួយក្នុងកំឡុងពេលអនុវត្តកម្មវិធីរបស់ខ្លួន ប្រតិបត្តិករមានសមត្ថភាពក្នុងការធ្វើអន្តរាគមន៍ និងប្តូរទិសដៅឡើងវិញ ដោយចេញបញ្ជាថ្មី ឬបិទវាចោលតែម្តង។ ខណៈពេលដែលអាវុធស្វយ័តពេញលេញនឹងកាត់ចោលការចូលរួមរបស់មនុស្សក្នុងការបើក និងបិទម៉ាស៊ីនតែម្តង។

“ខណៈពេលដែលអាវុធស្វយ័តពេញលេញនឹងកាត់ចោលការចូលរួមរបស់មនុស្សក្នុងការបើក និងបិទម៉ាស៊ីនតែម្តង”

ទោះយ៉ាងណា ការបិទម៉ាស៊ីនស្វយ័តពេញលេញអាចមានដែនកំណត់របស់វា។ ឧ.យ៉ាង ប្រសិនបើយានអវកាសគ្មានមនុស្ស បើកត្រូវបានបាញ់ចេញពីកប៉ាល់នៅកណ្តាលសមុទ្រទៅកាន់គោលដៅដែលគ្មានប្រតិបត្តិករ ពួកគេប្រហែលជាមិនអាចតាមដានសកម្មភាពរបស់វាទាំងស្រុង ឬអាចបញ្ជូនសញ្ញាដើម្បីបិទវាបានទេ។ វាមានអត្ថប្រយោជន៍ជាច្រើនចំពោះស្វ័យភាពរបស់ម៉ាស៊ីនដែលធ្វើឱ្យវាមានសុវត្ថិភាពពីការកកស្ទះ ឬការលួចចូល ប៉ុន្តែវាក៏មានកម្រិតហានិភ័យខ្ពស់ផងដែរដែលមិនអាចទស្សន៍ទាយសកម្មភាពរបស់ម៉ាស៊ីនបានទាំងស្រុង ហើយបញ្ឈប់វាបានក្នុងករណីដែលវាដំណើរការមិនត្រឹមត្រូវ[13] ■

13 Scharre, P. (2018). Army of none: Autonomous weapons and the future of war. New York: W.W. Norton.

ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់: បញ្ហាសកល

ហេតុអ្វីបានជាប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់គឺ ជាបញ្ហាសកល?

បច្ចុប្បន្ននេះ មានតែពីរ ឬបីប្រទេសប៉ុណ្ណោះដែលមានសមត្ថភាពអាចផលិតប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) ហើយមានប៉ុន្មានប្រទេសផ្សេងទៀតដែលមានសមត្ថភាពទិញប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ទាំងនោះបាន។ ការរំពឹងទុកនៃសង្គ្រាមដែលមានប្រសិទ្ធិភាពជាងមុន ដែលត្រូវបានធ្វើអាជីវកម្មផ្តាច់មុខដោយប្រទេសមួយចំនួនគឺបណ្តាលឱ្យមានការព្រួយបារម្ភសម្រាប់ប្រទេសដទៃទៀតដែលអាចនឹងទទួលរងនូវផលប៉ះពាល់នេះ។ ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយជុំវិញពិភពលោកជម្លោះផ្ទៃក្នុង និងភាពវឹកវរក្នុងសង្គមដែលមិនទាក់ទងនឹងជម្លោះ អាចដើរតួជាកត្តាជម្រុញដល់ការកើនឡើង និងការរីករាលដាលនៃអំពើហិង្សាប្រដាប់អាវុធ។ ដូចដែលបានរៀបរាប់ខាងលើ ប្រព័ន្ធអាវុធស្វយ័ត (AWS) មិនចាំបាច់ទាល់តែសាហាវទើបបង្កឲ្យមានគ្រោះថ្នាក់ដល់ជីវិតនោះទេ។ ប្រភេទប្រព័ន្ធអាវុធស្វយ័ត (AWS) មួយចំនួននៅតែអាចបណ្តាលឱ្យមានការរីករាលដាលនៃគ្រោះថ្នាក់ភ្លាមៗ ខណៈដែលមនុស្សមានសមត្ថភាពអាចគិតលើសពីការបញ្ជា និងប្រើប្រាស់ភាពអត់ធ្មត់របស់ខ្លួន។



មានតែពីរ ឬបីប្រទេសប៉ុណ្ណោះកំពុងផលិតប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS)
ប្រភព: យុទ្ធនាការបញ្ឈប់មនុស្សយន្តពិឃាដ[14]

14 Russell, S. (2016, January 17). Robots in war: The next weapons of mass destruction? World Economic Forum. Retrieved from https://www.weforum.org/agenda/2016/01/robots-in-war-the-next-weapons-of-mass-destruction/.

វាក៏មានភាពមិនច្បាស់លាស់ខ្លះដែរ នៅពេលដាក់ពង្រាយអាវុធស្វយ័តពេញលេញ។ ក្រុមសិទ្ធិមនុស្សអន្តរជាតិបានលើកឡើងពីការព្រួយបារម្ភអំពីក្រមសីលធម៌របស់ម៉ាស៊ីនដែលអាចសម្លាប់មនុស្សដោយគ្មានព្រំដែននៃទំនួលខុសត្រូវច្បាស់លាស់។ គេនៅតែរង់ចាំមើលថាតើម៉ាស៊ីនមួយអាចត្រូវបានគេបង្រៀនឱ្យចេះគោរពតាមច្បាប់ជម្លោះប្រដាប់អាវុធ (LOAC) ជាពិសេសច្បាប់មនុស្សធម៌អន្តរជាតិ(IHL) ដែរឬទេ។ តួយ៉ាង យុទ្ធជនដែលចុះចាញ់មិនត្រូវបានគេចាត់ទុកថាជាយុទ្ធជនទៀតទេ ដូច្នេះហើយមិនគួរក្លាយជាគោលដៅទៀតឡើយ។ បច្ចេកវិទ្យាអាចជំណើរការខុសប្រក្រតី ឬអាចរត់គេចពីការត្រួតពិនិត្យរបស់ប្រតិបត្តិករមនុស្សរបស់វា។ សូម្បីតែក្នុងករណីដែលមនុស្សយន្តអាចធ្វើសកម្មភាពបានកាន់តែច្បាស់ជាងមុន និងធ្វើការសម្រេចចិត្តដោយស្វយ័តក្តី ក៏មនុស្សនៅតែត្រូវបានគេរួមបញ្ចូល ដើម្បីរក្សាការគ្រប់គ្រងត្រួតពិនិត្យ ដែលប្រៀបដូចជាការមានកម្មវិធីបញ្ឈប់គ្រោះអាសន្នដូចនោះដែរ។

ការព្រមានដ៏សំខាន់មួយទៀតដែលគួរតែត្រូវបានគេពិចារណានោះ គឺជាកង្វះនយោបាយអន្តរជាតិដែលធ្វើនិយ័តកម្មពាណិជ្ជកម្មអន្តរជាតិ និងការផ្ទេរប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) ភាពស្មុគស្មាញនៃផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងធាតុផ្សំរបស់វា។ ប្រទេសជាច្រើននៅក្នុងពិភពលោក នៅតែទទួលរងគ្រោះពីជម្លោះប្រដាប់អាវុធផ្ទៃក្នុងដែលកាន់តែមានសភាពធ្ងន់ធ្ងរទៅ។ ដោយសារការរីកសាយនៃអាវុធខុសច្បាប់។ ការរីករាលដាលនៃប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ដោយខុសច្បាប់ អាចត្រឹមតែធ្វើឲ្យជម្លោះបែបនេះកាន់តែមានភាពធ្ងន់ធ្ងរឡើងប៉ុណ្ណោះ។ កម្មវិធីសូហ្វវ៉ែរ ដែលត្រូវបានប្រើក្នុងការរកចាប់យកប្រធានបទនេះគឺមានរួចជាស្រេចហើយ ហើយមនុស្សក៏អាចចូលមើលតាមប្រព័ន្ធអ៊ីនធើណែតបានយ៉ាងងាយស្រួលទៀតផង។ ដរាបណាទាល់តែក្រុមដែលគ្មានការអនុញ្ញាតអាចត្រូវបានរាំងពីការទទួលបានប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) និងផ្នែករបស់វានោះការប្រុងប្រយ័ត្នខ្ពស់គួរតែត្រូវបានអនុវត្តក្នុងការអភិវឌ្ឍ និងដាក់ពង្រាយពួកវា។ ■

តើមានអំណះអំណាងអ្វីខ្លះដែលយល់ស្របឲ្យមានប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់?

មតិមួយចំនួនបានចង្អុលបង្ហាញពីអត្ថប្រយោជន៍នៃការអភិវឌ្ឍប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) សម្រាប់ការប្រើប្រាស់ក្នុងសង្គ្រាម។ ក្នុងចំណោមធាតុបីដែលត្រូវបានគេលើកឡើងច្រើនជាងគេរួមមាន ល្បឿន ភាពជាក់លាក់ និងប្រសិទ្ធភាព[15]។ ភាពជាក់លាក់គឺមានសារៈសំខាន់ណាស់ ជាពិសេសនៅក្នុងសមរភូមិដើម្បីកាត់បន្ថយចំនួនអ្នកស្លាប់ និងរបួសឱ្យបានតិចបំផុតតាមដែលអាចធ្វើទៅបាន។ នៅតំបន់ទីក្រុងជាទូទៅពិបាកក្នុងការស្វែងរក កំណត់អត្តសញ្ញាណ និងពាក់ព័ន្ធដល់គោលដៅដែលកំពុងធ្វើចលនាយ៉ាងសកម្ម។ កងកម្លាំងដែលលាក់ខ្លួននៅពីក្រោយជនស៊ីវិលអាចត្រូវគេកំណត់គោលដៅបានដោយមិនបង្កឲ្យមានគ្រោះថ្នាក់ដល់អ្នកដែលមិនមែនជាអ្នកប្រយុទ្ធ។ តាមគោលការណ៍ ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) អាចមានសមត្ថភាពកាន់តែច្រើនក្នុងការកំណត់គោលដៅត្រឹមត្រូវ និងការពារយុទ្ធជន បើប្រៀបធៀបទៅនឹងមនុស្ស រួមទាំងយុទ្ធជនដែលមានការបណ្តុះបណ្តាលល្អ[16]។ ប្រទេសចិនបានបំពាក់រថក្រោះចាស់ៗរបស់ខ្លួនមួយចំនួនរួចជាស្រេចហើយជាមួយនឹងប្រព័ន្ធការពារសកម្ម ខណៈពេលដែលប្រទេសកូរ៉េខាងត្បូងអាចបន្ថែមរបាំងការពារមួយទៀត ដោយបានបំពាក់មនុស្សយន្តយាមការរបស់ខ្លួននៅក្នុងតំបន់គ្មានយោធា (DMZ)[17] ■

15 Altmann, J. & Sauer, F. (2017). Autonomous weapon systems and strategic stability. Survival, 59(5), 117-142.; Fanning, D. (Producer), & Fanning, D. & Docherty, N. (Directors). (2019). In the age of AI [Documentary film]. United States: PBS.; Scharre, P. (2018). Army of none: Autonomous weapons and the future of war. New York: W.W. Norton.

16 Scharre, P. (2018). Army of none: Autonomous weapons and the future of war. New York: W.W. Norton.

17 Kania, E.B. (2020, April). "AI weapons" in China's military innovation. The Brookings Institution. Retrieved from https://www.brookings.edu/research/ai-weapons-in-chinas-military-innovation/.

"មតិមួយចំនួនបានចង្អុលបង្ហាញពីអត្ថប្រយោជន៍នៃការអភិវឌ្ឍប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) សម្រាប់ការប្រើប្រាស់ក្នុងសង្គ្រាម។ ក្នុងចំណោមធាតុបីដែលត្រូវបានគេលើកឡើងច្រើនជាងគេរួមមាន ល្បឿន ភាពជាក់លាក់ និងប្រសិទ្ធភាព។"

តើមានអំណះអំណាងអ្វីខ្លះដែលប្រឆាំងនឹងប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់?

ខណៈពេលដែលប្រព័ន្ធអាវុធស្វយ័ត ដែលមានស្រាប់ភាគច្រើនត្រូវបានប្រើប្រាស់ជាចម្បងនៅក្នុងកងកម្លាំងការពារ មានការព្រួយបារម្ភជាច្រើនទាក់ទងនឹងភាពសមស្របនៃការប្រើប្រាស់របស់វា ក៏ដូចជាអ្នកដែលទទួលខុសត្រូវចំពោះសកម្មភាពរបស់វា។

ការជំទាស់ទៅនឹងប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់(LAWS)ជាទូទៅផ្តោតលើអំណះអំណាងចំនួន៣ គឺភាពមិនអាចទាយទុកជាមុនបាននៃបញ្ញាសិប្បនិមិត្តរៀនសូត្រស៊ីជម្រៅ ភាពមិនច្បាស់អំពីថាតើភាពឆ្លាតវៃអនុញ្ញាតឱ្យបញ្ញាសិប្បនិមិត្ត (AI) អាចយល់ពីភាពលំបាក និងបរិបទខាងសីលធម៌ និងសក្តានុពលនៃប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) ក្នុងការប្រើប្រាស់នៅក្នុងស្ថានភាពដោយអចេតនា ដោយគ្មានការអនុញ្ញាត និងជាយថាហេតុ។

ទី១ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកមុន ការរៀនសូត្ររបស់ម៉ាស៊ីនអាចប្រើក្បួនដោះស្រាយជាច្រើន ប៉ុន្តែប្រហែលជាមិនតែងតែផ្តល់លទ្ធផលត្រឹមត្រូវរហូតនោះទេ។ កម្មវិធីសូហ្វវ៉ែរសម្គាល់រូបភាពដែលត្រូវបានគេបំពាក់ដោយសមត្ថភាពសិក្សាស៊ីជម្រៅ បានបង្ហាញថាវាអាចបង្កើតការយល់ដឹងផ្ទាល់ខ្លួនពីរូបភាព។ ជំនួសឱ្យការផ្ទូផ្ទងវាជាមួយរូបភាពនៅក្នុងប្រព័ន្ធទិន្នន័យរបស់វា វាសម្គាល់រូបនោះជាមួយរូបភាពដែលវាបង្កើតដោយខ្លួនឯង ដែលជាធម្មតាមានលក្ខណៈជារូបភាពអរូបីមិនសមហេតុសមផល និងប្រឌិតទាំងស្រុង។ មនុស្សអាចមានសមត្ថភាពវែកញែក ប៉ុន្តែម៉ាស៊ីនដែលមានលទ្ធភាពរៀនសូត្រស្ទើរតែគ្មានដែនកំណត់នឹងធ្វើឱ្យមានការកំណត់ខុសគ្នា។ លើសពីនេះទៅទៀត ដោយសារតែបញ្ញាសិប្បនិមិត្ត(AI)តែងតែត្រូវបានគេធ្វើតេស្តនៅក្នុងមន្ទីរពិសោធន៍ នោះវាមិនមានការបញ្ជាក់អំពីកំហុស ឬដំណើរការខុសប្រក្រតីណាមួយនឹងលេចចេញនោះទេ នៅពេលវាត្រូវបានគេយកទៅប្រើប្រាស់ក្នុងពិភពពិតខាងក្រៅ។ អាវុធបំពាក់ដោយបញ្ញាសិប្បនិមិត្ត(AI)ដែលត្រូវបានដាក់ពង្រាយក្នុងជម្លោះជាមួយនឹងការធ្វើតេស្តសាកល្បងតិចតួចបំផុត គឺពិតណាស់ជាអាវុធដែលមិនបានឆ្លងកាត់ការធ្វើតេស្តសាកល្បង និងអាចផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរជាងផ្តល់ផលល្អ។

ទី២ មនុស្សជាតិអាចជ្រើសរើសប្រឆាំងនឹងបញ្ហាប្រសិនបើពួកគេជួបប្រទះនឹងបញ្ហាខាងក្រមសីលធម៌ដូចជាការជ្រើសរើសមិនយកកុមារឬអ្នកផ្តល់ព័ត៌មានធ្វើជាគោលដៅ[18]។ តួយ៉ាង តើជនស៊ីវិលដែលប្រើប្រាស់អាវុធដើម្បីការពារទ្រព្យសម្បត្តិរបស់ពួកគេត្រូវបានគេចាត់ទុកថាជាគូសត្រូវប្រយុទ្ធដែរឬទេ?

18 Scharre, P. (2018). Army of none: Autonomous weapons and the future of war. New York: W.W. Norton.

ទី៣ តើត្រូវប្រើប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) យ៉ាងដូចម្តេច ដើម្បីធានាថាវាត្រូវបានប្រើដោយត្រូវនឹងចេតនា និងការកំណត់ទុកមុនដោយប្រុងប្រយ័ត្ន។ មានធាតុផ្សំជាច្រើនក្នុងការបង្កើតប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) រួមបញ្ចូលទាំងកម្មវិធីសូហ្វវែរដែលមានកម្មវិធីបញ្ញាសិប្បនិមិត្ត និងផ្នែកជាច្រើននៃផ្នែករឹង(hardware)។ កម្មវិធីសូហ្វវែរសម្រាប់កំណត់អត្តសញ្ញាណរូបភាពគឺអាចរកបានជាសាធារណៈ ដែលត្រូវបានបង្កើតដាច់ដោយឡែកពីគ្នាដោយក្រុមហ៊ុនបញ្ញាសិប្បនិមិត្ត(AI) ជាច្រើន។ បច្ចេកវិទ្យាជ្រូនក៏ត្រូវបានគេបង្កើតរួចរាល់និងអាចរកបានផងដែរ ដោយមានការប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម នៅក្នុងវិជ្ជាជីវៈមួយចំនួន (ជាឧទាហរណ៍ដូចជា ការថតរូប)។ ប្រសិនបើភាគីដែលគ្មានការអនុញ្ញាតអាចទទួលបាននូវធាតុផ្សំផ្សេងៗច្រើនមុខ នោះវានឹងបង្កឲ្យមានគ្រោះថ្នាក់នៃការរីកសាយប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) ដែលពិបាកនឹងគ្រប់គ្រងបាន។ បើគ្មានការយល់ដឹងដោយប្រុងប្រយ័ត្នអំពីវដ្តជីវិតនៃប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) និងធាតុផ្សំរបស់វាទេ ក្រុមប្រដាប់អាវុធមិនមែនរដ្ឋនឹងអាចទទួលបានសិទ្ធិប្រើប្រាស់ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) និងប្រើប្រាស់វាដើម្បីប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាល ឬប្រព្រឹត្តបទឧក្រិដ្ឋកម្មផ្សេងៗ។ ■

តើប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ ជះឥទ្ធិពលអ្វីខ្លះដល់ច្បាប់មនុស្សធម៌?

ប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS) អាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ នៅពេលដែលត្រូវបានដាក់ពង្រាយទាំងនៅកន្លែងមានជម្លោះនិងមិនមានជម្លោះ។ ដោយសារតែល្បឿន និងប្រសិទ្ធភាពនៃប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS) ដើម្បីកម្ទេចគោលដៅ ឬប្រព័ន្ធអាវុធស្វយ័ត (AWS) ដើម្បីបន្ថយភាពធន់របស់សត្រូវ ចំនួនអ្នកស្លាប់ និងគ្រោះថ្នាក់អាចកើនឡើងយ៉ាងខ្លាំងនៅពេលដែលប្រព័ន្ធអាវុធទាំងនេះត្រូវបានប្រើប្រាស់។ ការត្រួតត្រាផ្នែកយោធាពេញលេញនឹងធ្វើឱ្យការបង្កសង្គ្រាមកាន់តែមានភាពងាយស្រួល និងឆាប់រហ័ស ដែលបណ្តាលឲ្យការប្រើដំណោះស្រាយសន្តិភាព និងការទូតកាន់តែថយចុះ។ ■

តើប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ រំលោភសិទ្ធិមនុស្សដែរឬទេ?

ការអភិវឌ្ឍ និងការប្រើប្រាស់ប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS) អាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្សទាក់ទងនឹងសុវត្ថិភាពរាងកាយ គណនេយ្យភាព និងប្រជាធិបតេយ្យ។ វាមិនច្បាស់ទេថាតើប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់(LAWS)នឹងធ្វើសកម្មភាពយ៉ាងដូចម្តេចនៅក្នុងជម្លោះក្នុងពិភពជាក់ស្តែងទាំងដែលបាន ឆ្លងកាត់ការសាកល្បងតិចតួច ឬមិនបានឆ្លងកាត់ការសាកល្បងទាល់តែសោះ។ ហេតុដូចនេះហើយ វានឹងបង្កើនហានិភ័យដែលអាចបង្កគ្រោះថ្នាក់ដល់រាងកាយ និងការបំផ្លិចបំផ្លាញថែមទៀតផងដែរ។ នៅពេលដែលមានបញ្ហាខុសប្រក្រតី ឬការធ្វើខុសកើតឡើង ការទទួលខុសត្រូវចំពោះសកម្មភាពនៃប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) និងប្រព័ន្ធអាវុធស្វយ័ត (AWS) គឺមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ។ នៅពេលមិនទាន់មានគណនេយ្យភាពបែបនេះ វាពិបាកក្នុងការឲ្យបុគ្គល ឬបទបញ្ជាណាមួយទទួលខុសត្រូវ។ ផលប៉ះពាល់លើលទ្ធិប្រជាធិបតេយ្យគឺអវិជ្ជមាន។ ជម្លោះអាចកើនឡើងដោយសារភាពងាយស្រួល ហើយសង្គ្រាមនឹងកើតឡើងដោយគ្មានការយល់ព្រមពីប្រជាជន។ គ្រោះថ្នាក់ និងការបាត់បង់ជីវិតនៅតែកើតឡើង ដោយគ្មានការធានាថាតើខ្សែសង្វាក់នៃទំនួលខុសត្រូវអាចត្រូវបានបង្កើតឡើងដែរ ឬអត់។ ■

តើស្ត្រីទទួលរងផលប៉ះពាល់យ៉ាងដូចម្តេចពីការរីកសាយនៃប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់?

អំពើហឹង្សាប្រឆាំងនឹងភេទគឺជាបញ្ហាកំពុងរីករាលដាលមួយ ដែលជះឥទ្ធិពលមិនស្មើគ្នាទៅលើស្ត្រី។ នៅក្នុងជម្លោះ ស្ត្រីងាយនឹងរងគ្រោះ ហើយអាចប្រឈមនឹងអំពើហិង្សាលើរាងកាយ និងការរំលោភផ្លូវភេទ ព្រមទាំងអំពើហិង្សាក្នុងទម្រង់ផ្សេងទៀត និងការបាត់បង់ឱកាសផ្សេងៗទៀត ដោយសារតែផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធទៅលើជីវិតរបស់ពួកគេ និងសង្គម។ការដាក់ពង្រាយប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) នៅក្នុងសង្គ្រាមមិនបានធានាដល់ការការពារស្ត្រីនៅក្នុងជម្លោះនោះទេ ជាពិសេសប្រឆាំងនឹងអំពើហិង្សាផ្លូវភេទ។ ហើយវាក៏មិនបានការពារស្ត្រីនៅក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ដែលជាកន្លែងដែលប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) មិនត្រូវបានគេប្រើប្រាស់។ ប្រសិនបើមាន វានៅតែមានចម្ងល់ថាតើម៉ាស៊ីនអាចអភិវឌ្ឍន៍ការយល់ដឹងអំពីសិទ្ធិមនុស្ស និងសេចក្ដីថ្លៃថ្នូរ និងមានសមត្ថភាពអាចបែងចែកការគំរាមកំហែងមិនត្រឹមតែទាក់ទងនឹងភាពសាហាវ រឺភាពផ្ទុយគ្នារវាងដៃគូ ឬគូសត្រូវប្រយុទ្ធនោះទេ ប៉ុន្តែក៏ទាក់ទងនឹងអំពើហិង្សា និងការបៀតបៀនផ្លូវភេទផងដែរ។ ■

ប្រសិនបើប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ត្រូវបានប្រើប្រាស់ តើនរណាជាអ្នកទទួលខុសត្រូវ?

តាមទ្រឹស្ដី ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) គួរតែមានសមត្ថភាពអាចកំណត់ ឬវាយតម្លៃកម្រិតនៃការគំរាមកំហែងដោយស្វ័យប្រវត្តិ។ ដូចដែលបានរៀបរាប់ខាងដើម ក្នុងករណីមានកំហុស ឬការបាត់បង់ ជីវិតរបស់ជនស៊ីវិល ខ្សែសង្វាក់នៃការទទួលខុសត្រូវ និងគណនេយ្យភាពគឺត្រូវបានបិទបាំងដោយគ្មានការគ្រប់គ្រងរបស់មនុស្សដែលមានអត្ថន័យចំពោះប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS)ទេ។ គណនេយ្យភាព និងសិទ្ធិមនុស្សត្រូវបានផ្សារភ្ជាប់គ្នាជាមូលដ្ឋាន។ ការគ្រប់គ្រងរបស់មនុស្សផ្ដល់មធ្យោបាយដល់ការទទួលស្គាល់សិទ្ធិមនុស្ស ការគោរពប្រតិបត្តិតាមច្បាប់ជម្លោះប្រដាប់អាវុធ (LOAC) និងច្បាប់មនុស្សធម៌អន្តរជាតិ (IHL) និងអំណាចនៃការទប់ស្កាត់ បើប្រៀបធៀបទៅនឹងភាពត្រឹមត្រូវនិងបញ្ញាសិប្បនិមិត្តដែលមានការយល់ដឹងតិចជាងនៅក្នុងប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS)។ ■

តើប្រទេសណាខ្លះបានកំពុងតែផលិតប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់រួចទៅហើយ?

ជាប្រវត្តិសាស្ត្រ សហរដ្ឋអាមេរិក និងអតីតសហភាពសូវៀតបានឈានមុខគេក្នុងការផលិតគ្រឿងអាវុធស្វយ័តដើម្បីប្រកួតប្រជែងគ្នាក្នុងអំឡុងសង្គ្រាមត្រជាក់។ វាបានចាប់ផ្តើមជាមួយនឹងប្រព័ន្ធមីស៊ីលព្រមានដំបូង ដែលត្រូវបានរចនាឡើងដើម្បីចាប់យកមីស៊ីលនៅក្នុងចំងាយជាក់លាក់មួយ[19]។ ខណៈពេលសង្គ្រាមរីករាលដាលដែលបានសម្លាប់ទាហាន និងប្រជាជនធម្មតាជាច្រើននាក់ និងធ្វើឲ្យជម្លោះកាន់តែចំណាយអស់ច្រើន ឬថ្លៃជាងមុន ប្រភេទអាវុធថ្មីៗត្រូវបានគេរចនាឡើងដើម្បីបង្កើនប្រសិទ្ធភាពនៃការពាក់ព័ន្ធដល់សត្រូវ ខណៈពេលដំណាលគ្នាដែរបានកាត់បន្ថយគ្រោះថ្នាក់នៃសង្គ្រាម។

19 Ibid

បញ្ជីឈ្មោះខ្លះៗនៃអាវុធពាក់កណ្តាលស្វយ័ត និងស្វយ័តពេញលេញ ដែលកំពុងសកម្ម និងស្ថិតក្នុងការអភិវឌ្ឍ
ប្រភព: Bode និង Huelss; (រូបភាព) NISEA[20]

អាវុធទាំងនេះ មួយចំនួនគឺស្វយ័តពេញលេញ ដូចជា IAI Harpy ឬ Harop។ មានឱកាសតិចតួចណាស់ដែលអាចបញ្ឈប់គ្រាប់បែកផ្លោងមិនឲ្យកម្ទេចគោលដៅរបស់ពួកគេនៅពេលដែលពួកវាត្រូវបានគេរចនាឡើងដើម្បីឈរជើង និងវិភាគតំបន់ជាក់លាក់មួយដើម្បីឃ្លាំមើលសកម្មភាពរបស់សត្រូវជាច្រើនម៉ោង។ IAI Harop ត្រូវបានគេស្គាល់ថាជាយន្តហោះជ្រូនធ្វើអត្តឃាត ព្រោះខ្លួនវាផ្ទាល់គឺជាគ្រាប់បែក។ វាត្រូវបានរចនាឡើងដើម្បីទម្លាក់ និងបំផ្ទុះលើគោលដៅបន្ទាប់ពីកំណត់អត្តសញ្ញាណហើយ។ ទោះបីជា Samsung SGR-A ដែលជាមនុស្សយន្តយាមការត្រូវបានបង្កើតឡើងដោយប្រទេសកូរ៉េខាងត្បូង ត្រូវបានរចនាឡើងដើម្បីកំណត់អត្តសញ្ញាណគោលដៅជាមនុស្សក្តី ក៏វាមិនអាចបែងចែករវាងដៃគូប្រយុទ្ធ និងសត្រូវ និងមិនអាចឈរជើងដោយសេរីបានឡើយ។
នៅអាស៊ី រដ្ឋាភិបាលឈានមុខគេដែលជម្រុញការស្រាវជ្រាវអំពីប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) មានដូចជាប្រទេសចិន កូរ៉េខាងត្បូង និងឥណ្ឌា ដោយមានប្រទេសមួយចំនួនទៀតដូចជាសិង្ហបុរី និងថៃក៏កំពុងពិចារណាដើម្បីបង្កើនសមត្ថភាពកងយោធា និងអនុវត្តន៍ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) របស់ខ្លួនផងដែរ។ នៅក្នុងការសិក្សាដែលដឹកនាំដោយស្ថាប័នអហិង្សាអន្តរជាតិអាស៊ីអាគ្នេយ៍ (NISEA) បានបង្ហាញថាអនុតំបន់នីមួយៗនៅអាស៊ីមានការលើកទឹកចិត្តខុសៗគ្នាក្នុងការពិចារណាលើការអភិវឌ្ឍប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS) នេះ។[21]

តួយ៉ាង នៅអាស៊ីបូព៌ា បញ្ហាសន្តិសុខជាមួយប្រទេសកូរ៉េខាងជើងបានជម្រុញប្រទេសកូរ៉េខាងត្បូងឱ្យបន្តការស្រាវជ្រាវផ្នែកបញ្ញាសិប្បនិមិត្ត(AI)ប្រើប្រាស់នៅក្នុងសព្វាវុធ។ ប្រទេសកូរ៉េខាងត្បូងបានដាក់ពង្រាយមនុស្សយន្តយាមការមួយគ្រឿងឈ្មោះ Samsung SGR-A នៅក្នុងតំបន់គ្មានយោធា (DMZ)។ ប្រទេសនេះក៏បានទិញអាវុធស្វយ័តពេញលេញមួយចំនួនផងដែរ ដូចជា IAI Harpy[22] ។ ទន្ទឹមនឹងនេះ ប្រទេសចិនបានធ្វើការយ៉ាងសកម្មក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍បញ្ញាសិប្បនិមិត្ត A ដោយព្យាយាមយកឈ្នះសហរដ្ឋអាមេរិកក្នុងនាមជាអ្នកអភិវឌ្ឍបញ្ញាសិប្បនិមិត្ត(AI)លំដាប់កំពូលនៅលើពិភពលោកឲ្យបានត្រឹមឆ្នាំ២០២៥។ ប្រទេសចិនគឺជាអ្នកនាំចេញអាវុធទូទាំងពិភពលោក ហើយក៏បានចាប់ផ្តើមនាំចេញនូវប្រព័ន្ធស្វយ័ត្តកម្មដោយគ្មានមនុស្ស។ ប្រព័ន្ធមួយបែបនេះគឺជាបែបបទ Wing Loong និងបែបបទ CH-4 ដែលទាំងពីរប្រភេទនេះជា

20 Bode, I. & Huelss, H. (2018). Autonomous weapons systems and changing norms in international relations. Review of International Studies, 44(3), 393-413, p. 402.; Austero, M. & Savage, P. (eds.) (2020). Artificial intelligence, emerging technology and lethal autonomous weapons systems: Security, moral and ethical perspectives in Asia. Retrieved from: https://www.stopkillerrobots.org/wp-content/uploads/2020/05/NISEA-AI-Emerging-Tech-and-LAWS-Perspectives-in-Asia.pdf
21 Austero, M. & Savage, P. (eds.) (September 2020). Artificial intelligence, emerging technology and lethal autonomous weapons systems: Security, moral and ethical perspectives in Asia.
22 PAX. 2019. State of AI: Artificial Intelligence, the Military and Increasingly Autonomous Weapons. Utrecht: PAX. April. Retrieved from https://www.paxforpeace.nl/media/files/state-of-artificial-intelligence--pax-report.pdf

យានអវកាសគ្មានមនុស្សបើក (UAV)[23]។ យានអវកាសគ្មានមនុស្សបើក UA)មួយទៀតដែលត្រូវបានប្រើប្រាស់ដោយ PL គឺ GJ-2 មានសមត្ថភាពហោះហើរស្វយ័ត និងធ្វើការវាយប្រហារជាក់លាក់[24]។ ផលិតកម្មបែបបទ C -4 ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសប៉ាគីស្ថាន មីយ៉ាន់ម៉ា និងអារ៉ាប់ប៊ីសាអូឌីត[25]។ ខណៈពេលដែលប្រទេសជប៉ុនអាចជាប្រទេសអភិវឌ្ឍដែលមានសមត្ថភាពអភិវឌ្ឍអាវុធជឿនលឿន ប៉ុន្តែខ្លួនបានប្រកាសជាសាធារណៈម្តងហើយម្តងទៀតថាខ្លួននឹងមិនចូលរួមក្នុងសកម្មភាពបែបនេះទេ ទោះបីជាខ្លួនត្រូវបានប្រកាសនៅក្នុងកិច្ចប្រជុំអន្តរជាតិស្តីពីប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) ក្រោមអនុសញ្ញាស្តីពីអាវុធធម្មតាមួយចំនួន (CCW)[26] ដោយ

នៅអាស៊ីអាគ្នេយ៍ គេឃើញមានការចាប់ផ្តើមប្រើប្រាស់យានគ្មានមនុស្សបើក ជាក់ស្តែងដូចជាការធ្វើពិសោធន៍របស់ប្រទេសថៃដែលបានប្រើយានលើដីគ្មានមនុស្សបើក (UGV)។ រហូតមកដល់ពេលនេះ ប្រទេសសិង្ហបុរីបានខិតខំប្រឹងប្រែងខ្លាំងជាងគេ ដោយបានបង្កើតមនុស្សយន្តការពារប្រដាប់អាវុធដើម្បីផ្តល់សន្តិសុខបន្ថែមដល់កងទ័ព ក៏ដូចជា “សុនខយន្ត” ដែលអនុវត្តវិធានការណ៍គម្លាតសង្គមនៅពេលមានការរីករាលដាលវីរុសកូវីដ១៩ខ្លាំងនៅក្នុងប្រទេស[27]។ ទោះបីជាផែនការទំនើបកយោធារបស់ខ្លួនបច្ចុប្បន្នមិនពាក់ព័ន្ធនឹងប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់(LAWS)ក្តី ក៏ហ្វីលីពីនបានផ្តួចផ្តើមការពិភាក្សាថ្នាក់ជាតិស្តីពីការប្រើប្រាស់ និងគ្រោះថ្នាក់របស់ខ្លួន។

នៅអាស៊ីខាងត្បូង បណ្តាប្រទេសភាគច្រើនមិនមានផែនការផលិតប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) ឬឈានទៅរកប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) នៅឡើយទេ លើកលែងតែប្រទេសឥណ្ឌាដែលបានប្រកាសផែនការដ៏អស្ចារ្យក្នុងការធ្វើទំនើបកម្មយោធារបស់ខ្លួន។ ប្រទេសប៉ាគីស្ថានបានប្រកាសថាខ្លួននឹងហាមឃាត់ការប្រើប្រាស់ និងការអភិវឌ្ឍប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS)[28]។ ■

តើកិច្ចពិភាក្សាក្នុងអនុសញ្ញាស្តីពីអាវុធធម្មតាមួយចំនួនស្តីអំពីបញ្ហាប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ដំណើរការដល់ណា?

នៅកម្រិតអន្តរជាតិ ទាំងកិច្ចពិភាក្សាផ្លូវការ និងក្រៅផ្លូវការស្តីពីប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) កំពុងមានការរីកចម្រើនជាបណ្តើរៗ ទោះបីជាមិនសូវមានកិច្ចពិភាក្សាថ្នាក់អន្តរជាតិត្រូវបានធ្វើឡើងជាផ្លូវការទាក់ទងនឹងប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) ក៏ដោយ។ បច្ចុប្បន្នកិច្ចពិភាក្សាការទូតត្រូវបានកំណត់ក្រោមក្របខ័ណ្ឌនៃអនុសញ្ញាស្តីពីអាវុធធម្មតាមួយចំនួន (CCW)។ កិច្ចប្រជុំក្រុមអ្នកជំនាញការរដ្ឋាភិបាលប្រចាំឆ្នាំ (GGE) ដែលបានចាប់ផ្តើមនៅខែវិច្ឆិកាឆ្នាំ២០១៧ ត្រូវបានធ្វើឡើងក្នុងចំណោមប្រទេសភាគីរបស់អនុសញ្ញាស្តីពីអាវុធធម្មតាមួយចំនួន (CCW) ដើម្បីស្វែងយល់ពីការវិវឌ្ឍ និងកង្វល់ជាសកលទាក់ទងនឹងការអភិវឌ្ឍន៍ និងការប្រើប្រាស់ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS)។ បន្ទាប់ពីកិច្ចប្រជុំទាំងនេះ និងដោយសារមានការយល់ដឹងកាន់តែទូលំទូលាយអំពីសក្តានុពលនៃប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS) កន្លងមកមានរដ្ឋាភិបាល១៩ បានគាំទ្រដល់ការហាមឃាត់ជាសាធារណៈនាពេលអនាគតលើប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS)[29] នេះ។ ■

23 Kania, E.B. (2020, April). “AI weapons” in China’s military innovation. The Brookings Institution. Retrieved from https://www.brookings.edu/research/ai-weapons-in-chinas-military-innovation/.
24 Ibid.
25 Ibid.
26 Austero, M. & Savage, P. (eds.) (2020). Artificial intelligence, emerging technology and lethal autonomous weapons systems: Security, moral and ethical perspectives in Asia. Retrieved from: https://www.stopkillerrobots.org/wp-content/uploads/2020/05/NISEA-AI-Emerging-Tech-and-LAWS-Perspectives-in-Asia.pdf
27 Ibid.
28 Ibid.
29 Bode, I. & Huelss, H. (2018). Autonomous weapons systems and changing norms in international relations. Review of International Studies, 44(3), 393-413; Scharre, P. (2018). Army of none: Autonomous weapons and the future of war. New York: W.W. Norton.

តើច្បាប់អន្តរជាតិអ្វីខ្លះពាក់ព័ន្ធនឹងប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់?

មិនមានកិច្ចព្រមព្រៀងអន្តរជាតិដែលមានស្រាប់ណាមួយបានចែងសម្រាប់តែបទប្បញ្ញត្តិនៃប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) ឬជំហានទៅរកប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS)នោះទេ។ ទោះបីជាយ៉ាងណា ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) ត្រូវបានចែងតាមបច្ចេកទេសនៅក្នុងប្រការ ម៉ាធិន (Martens) នៃអនុសញ្ញាទីក្រុងហ្សឺណែវអនុពិធីសារបន្ថែមទី២ ព្រោះវាទាក់ទងទៅនឹងបច្ចេកវិទ្យាដែលកំពុងរីកចម្រើនដែលមិនបានចែងដោយអនុសញ្ញានៅពេលនោះ។ ប្រការនេះចែងថា“ក្នុងករណីដែលមិនមានចែងក្នុងពិធីសារនេះ ឬដោយកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត ជនស៊ីវិល និងយុទ្ធជននៅតែស្ថិតក្រោមការការពារ និងសិទ្ធិអំណាចនៃគោលការណ៍នៃច្បាប់អន្តរជាតិ ដែលទទួលបានពីទំនៀមទម្លាប់ ដែលបានបង្កើតឡើងពីគោលការណ៍មនុស្សជាតិ និងពីមនសិការសាធារណៈ[30]។ ដូច្នេះ បណ្តាប្រទេសត្រូវតែធានាថាច្បាប់មនុស្សធម៌អន្តរជាត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធិភាពនៅក្នុងគ្រប់ជម្លោះ ដោយមិនគិតពីការជឿនលឿនទៅមុខនៃអាវុធក្នុងពេលអនាគត។

កិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតអាចគ្របដណ្តប់លើផ្នែក ឬធាតុផ្សំនៃបច្ចេកវិទ្យាដែលកំពុងរីកចម្រើននៅក្នុងប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS)។ សន្ធិសញ្ញាពាណិជ្ជកម្មអាវុធឆ្នាំ២០១២ (ATT) អនុសញ្ញាឆ្នាំ២០០៨ ស្តីពីគ្រាប់បែកចង្កោម (CCM) និងសន្ធិសញ្ញាហាមប្រាមមីនឆ្នាំ១៩៩៦ (MBT) សុទ្ធតែបានចែងអំពីផ្នែក ឬធាតុផ្សំនៃអាវុធបំពាក់ដោយបញ្ញាសិប្បនិមិត្ត (AI)។ គួរកត់សម្គាល់ផងដែរថា អនុសញ្ញាស្តីពីអាវុធធម្មតាមួយចំនួន (CCW) បានផ្តល់មធ្យោបាយសម្រាប់ការហាមឃាត់អាវុធដែលកំពុងស្ថិតក្នុងការអភិវឌ្ឍដូចជាអាវុធឡាសែរ ដែលអាចដើរតួជាគំរូសម្រាប់ការបង្កើតរបបបទបញ្ញត្តិផ្តាច់មុខស្តីពីប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS)[31]។ ដោយសារភាពស្មុគស្មាញនៃការអភិវឌ្ឍ និងការផលិតរបស់វា និងផ្នែក និងធាតុផ្សំ ផ្សេងៗដែលតម្រូវឲ្យមាននៅក្នុងការសាងសង់ប្រព័ន្ធអាវុធស្វយ័តពេញលេញ ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ (LAWS) ចាំបាច់ត្រូវមានកិច្ចព្រមព្រៀងអន្តរជាតិដាច់ដោយឡែកមួយដើម្បីបកស្រាយអំពីវដ្តជីវិត និងកង្វល់ផ្នែកក្រមសីលធម៌វិជ្ជាជីវៈដែលផុសចេញពីការអភិវឌ្ឍ និងការប្រើប្រាស់របស់វា។ ■

30 Protocol additional to the Geneva conventions of 12 August 1949, and relating to the protection of victims of international armed conflicts (Protocol I), 8 June 1977. Retrieved from https://ihl-databases.icrc.org/ihl.nsf/WebART/470-750004.

31 United Nations [UN]. (2001, December 21). Group of governmental experts of the high contracting parties to the convention on prohibitions or restrictions on the use of certain conventional weapons which may be deemed to be excessively injurious or to have indiscriminate effects as amended. Retrieved from https://www.unog.ch/80256EDD006B8954/(httpAssets)/40BDE99D98467348C12571DE0060141E/$file/CCW+text.pdf/.

ប្រទេសកម្ពុជា និងប្រព័ន្ធអាវុធ ស្វយ័តដ៏គ្រោះថ្នាក់

តើច្បាប់ជាតិរបស់ ប្រទេសកម្ពុជា ដែលទាក់ទងនឹង ប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់មានអ្វីខ្លះ?

ប្រទេសកម្ពុជាមិនទាន់មានច្បាប់ទាក់ទងទៅនឹងប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់នៅឡើយទេ ប៉ុន្តែប្រទេសកម្ពុជាមានច្បាប់គ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវដែលបានអនុម័តក្នុងខែមិថុនា ឆ្នាំ២០០៥[32]។ នាពេលបច្ចុប្បន្ននេះច្បាប់ឧក្រិដ្ឋកម្មតាមអ៊ីធើណិតបានកំពង់ស្ថិតនៅក្នុងការពិភាក្សា ឬពង្រាង។

ជំហររបស់ប្រទេសកម្ពុជាស្តីពីការរំសាយអាវុធជាច្រើនអាចត្រូវបានគេមើលឃើញតាមរយៈទិដ្ឋភាពរបស់ខ្លួនលើរបៀបវារៈទាក់ទងនឹងការដកហូតអាវុធមនុស្សធម៌ផ្សេងៗដូចខាងក្រោម៖

- ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញា**ការហាមឃាត់ការប្រើប្រាស់ ស្តុកទុក ផលិតកម្ម និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លិចបំផ្លាញ** កាលពីថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៩៧ ហើយបានផ្តល់សច្ចាប័នលើសន្ធិសញ្ញានេះ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩[33] ហើយបានក្លាយជារដ្ឋភាគី នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០០។ ច្បាប់អនុវត្តក្នុងស្រុកដែលជាច្បាប់ហាមឃាត់ការប្រើប្រាស់មីនប្រឆាំងមនុស្សបានចូលជាធរមាន នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៩។ ឆ្នាំ១៩៩៩ ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលទទួលបានជ័យជំនះលើសន្ធិសញ្ញាហាមប្រាមមីននៅអាស៊ី។

- ព្រះរាជាណាចក្រកម្ពុជាមិនបានចូលជាសមាជិកនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោមទេ។ ប្រទេសកម្ពុជាបានបង្ហាញចំណាប់អារម្មណ៍ចំពោះអនុសញ្ញានេះប៉ុន្តែមិនបានចាត់វិធានការណាមួយដើម្បីចូលរួមក្រៅពីការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធឡើយ ហើយបានធ្វើអត្ថាធិប្បាយចុងក្រោយលើបញ្ហានេះនៅខែមីនា ឆ្នាំ២០១៧ នៅពេលដែលមន្ត្រីកម្ពុជាម្នាក់បានប្រាប់សម្ព័ន្ធមិត្តគ្រាប់បែកចង្កោម (CMC) ថារដ្ឋាភិបាលចាត់ទុកអនុសញ្ញានេះជាវិជ្ជមាន ហើយសង្ឃឹមថានឹងចូលរួមនាពេលអនាគត។ កាលពីមុនក្នុងឆ្នាំ២០១៣ ដល់ ២០១៤ ប្រទេសកម្ពុជាបាននិយាយថាខ្លួនកំពុងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធផ្សេងៗលើសំណួរនៃការចូលជាសមាជិកនៃអនុសញ្ញានេះ[34]

32 https://www.jics.or.jp/jsac/Reports_Speeches/ArmsLaw.pdf
33 http://www.the-monitor.org/en-gb/reports/2013/cambodia/mine-ban-policy.aspx
34 http://the-monitor.org/en-gb/reports/2018/cambodia/cluster-munition-ban-policy.aspx

- ដែលកន្លងមកនេះប្រទេសកម្ពុជាបានចុះហត្ថលេខា ប៉ុន្តែមិនទាន់បានផ្តល់សច្ចាប៉ន លើសន្ធិសញ្ញាស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ។ លោក កេ សុវណ្ណ អ្នកតំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជាប្រ ចាំនៅអង្គការសហប្រជាជាតិ បានចុះហត្ថលេខាលើសន្ធិសញ្ញានេះនៅថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩។ ប្រទេសកម្ពុជាបានចូលរួមក្នុងការចរចានៃសន្ធិសញ្ញានេះនៅឯអង្គការសហប្រជាជាតិនៅញូវយ៉ក ក្នុងឆ្នាំ២០១៧ និងបានបោះឆ្នោតគាំទ្រការអនុម័តរបស់ខ្លួន។ ប្រទេសកម្ពុជាគឺជារដ្ឋភាគីនៃសន្ធិសញ្ញាទីក្រុងបាងកកឆ្នាំ ១៩៩៥ ដែលបានបង្កើតអាស៊ីអាគ្នេយ៍ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ[35]

- ជាមួយគ្នានេះផងដែរព្រះរាជាណាចក្រកម្ពុជាបានដាក់ឧបករណ៍របស់ខ្លួនក្នុងការផ្តល់សច្ចាប៉នលើអនុសញ្ញាស្តីពីអាវុធគីមីជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៥ ហើយនឹងក្លាយជារដ្ឋទី១៧០ នៃអនុសញ្ញា និងជារដ្ឋសមាជិកនៃអង្គការហាមឃាត់អាវុធសារធាតុគីមី (OPCW) នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៥[36]

- ប្រទេសកម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសដំបូងគេដែលបានឈ្នះសន្ធិសញ្ញាពាណិជ្ជកម្មអាវុធ (ATT) នៅពេលដែលប្រទេសនេះត្រូវបានអង្គការសហប្រជាជាតិយកចិត្តទុកដាក់ជាលើកដំបូង។ ប្រទេសកម្ពុជាជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញាពាណិជ្ជកម្មអាវុធ (ATT) ចាប់តាំងពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ តាមរយៈឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំអង្គការសហប្រជាជាតិ ប៉ុន្តែមិនទាន់បានបញ្ចប់ដំណើរការផ្តល់សច្ចាប៉ននៅឡើយទេ[37]។ ប្រទេសកម្ពុជាបានរៀបកិច្ចប្រជុំថ្នាក់តំបន់ជាច្រើនស្តីពីសន្ធិសញ្ញាពាណិជ្ជកម្មអាវុធ និងកម្មវិធីសកម្មភាពរបស់អង្គការសហប្រជាជាតិ ស្តីពីអាវុធធុនតូច និងអាវុធធុនស្រាល (UNPoA) ។ ■

ហេតុអ្វីបានជា ប្រទេសកម្ពុជា គួរគាំទ្រឲ្យមានការចរចាលើសន្ធិសញ្ញាថ្មីមួយស្តីពីប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់?

- ជាប្រវត្តិសាស្ត្រប្រទេសកម្ពុជាគឺជារដ្ឋរងគ្រោះនៃប្រព័ន្ធអាវុធផ្សេងៗ (ឧ) គ្រាប់មីន គ្រាប់បែកចង្កោម អំពើហឹង្សាប្រដាប់អាវុធកើតឡើង ដែលត្រូវបានបង្កើតឡើងដោយលំហូរអាវុធដែលមិនមានច្បាប់ ទម្លាប់។

- ប្រទេសកម្ពុជាគាប្បីធ្វើការពិភាក្សាលើបញ្ហាប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់នេះ។ ទោះបីប្រទេសកម្ពុជាមិនចាត់ទុកវាជាអាទិភាពក៏ដោយក៏មិនគួរឱ្យជាប្រទេសអភិវឌ្ឍន៍បច្ចេកវិទ្យា ឬអ្នកទិញបច្ចេកវិទ្យានោះដែរ។ មានបញ្ហាក្រមសីលធម៌និងសីលធម៌ជាច្រើនដែលគួរតែត្រូវបានដោះស្រាយជុំវិញការអភិវឌ្ឍប្រព័ន្ធអាវុធស្វ័យភាពដ៏គ្រោះថ្នាក់ ដែលរដ្ឋនីមួយៗរួមទាំងប្រទេសកម្ពុជាគួរតែអាចបញ្ចេញមតិរបស់ពួកគេ។

- ក្នុងនាមជាផ្នែកមួយនៃវេទិកាពហុភាគីដូចជាអង្គការសហប្រជាជាតិនៅតែជាវេទិកាតែមួយគត់ដើម្បីពិភាក្សាអំពីបញ្ហាប្រព័ន្ធអាវុធស្វយ័តដ៏គ្រោះថ្នាក់ជាសកល ដែលត្រូវការការចូលរួម និងផ្តល់យោបល់ពីរដ្ឋនិមួយៗលើបញ្ហាដែលពាក់ព័ន្ធ។

35 https://www.icanw.org/cambodia
36 https://www.opcw.org/media-centre/news/2005/07/cambodia-ratifies-chemical-weapons-convention
37 https://www.phnompenhpost.com/national/arms-trade-treaty-reviewed-asean

ហេតុអ្វីប្រទេសកម្ពុជាគួរគាំទ្រការហាមឃាត់ប្រព័ន្ធអាវុធស្វ័យភាពដ៏គ្រោះថ្នាក់?

- ប្រទេសកម្ពុជាបានប្រកាន់ខ្ជាប់ជានិច្ចនូវភាពចាំបាច់នៃមនុស្សធម៌។ ប្រទេសកម្ពុជាបានដឹកនាំសន្ធិសញ្ញាពាណិជ្ជកម្មអាវុធ និងបានគាំទ្រសន្ធិសញ្ញាហាមប្រាមមីន។ កម្ពុជាគួរតែឈរលើហេតុផលមនុស្សធម៌ជាប្រចាំចំពោះការហាមឃាត់ប្រព័ន្ធអាវុធស្វ័យភាពដ៏គ្រោះថ្នាក់នេះ។

- វាផ្តល់ផលប៉ះពាល់អស្ថិរភាព និងគំរាមកំហែងដល់សន្តិភាព និងសន្តិសុខអន្តរជាតិ។ អាវុធមានប្រតិកម្ម និងធ្វើអន្តរកម្មជាមួយគ្នាក្នុងល្បឿនហួសពីការគ្រប់គ្រងរបស់មនុស្ស ដែលវានឹងបង្កើនហានិភ័យនៃការរីកសាយអាវុធ ហើយដូច្នេះអាចឱ្យជនផ្តាច់ការ សកម្មជនប្រដាប់អាវុធមិនមែនរដ្ឋ ឬភេរវកមទទួលបានអាវុធស្វ័យតពេញលេញ។

- ដោយសារតែសម្ភារៈចាំបាច់សម្រាប់ផលិតអាវុធមានតំលៃថោក និងងាយស្រួលក្នុងការទទួលបានអំណាច យោធាអាចផលិតអាវុធទាំងនេះបង្កើនលទ្ធភាពនៃការរីកសាយអាវុធ និងការសម្លាប់រង្គាល។ ■

កិច្ចខិតខំប្រឹងប្រែង របស់សង្គមស៊ីវិល

ហេតុអ្វីប្រទេសកម្ពុជាគួរគាំទ្រការហាមឃាត់ ប្រព័ន្ធអាវុធស្វ័យភាពដ៏គ្រោះថ្នាក់?

អង្គការសង្គមស៊ីវិល (CSOs) បានចាប់ផ្តើមបង្កើនការយល់ដឹងអំពីគ្រោះថ្នាក់ដែលអាចកើតមាននិងការព្រួយ បារម្ភខាងសីលធម៌ វិជ្ជាជីវៈជុំវិញប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS)។ យុទ្ធនាការជាសកលដើម្បីបញ្ឈប់មនុស្សយន្តពិឃាដ (CSKR) ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងបញ្ហាក្រមសីលធម៌ និងសីលធម៌និងការសម្ងាត់ដទៃទៀតនៃការអភិវឌ្ឍន៍ប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS) ទូទាំងពិភពលោក។ មានការព្រួយបារម្ភកាន់តែខ្លាំងឡើងនៅពាសពេញពិភពលោកចំពោះការប្រើប្រាស់ប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS) ប្រឆាំងនឹងមនុស្សជាតិ ជាពិសេសជាមួយតួនាទីដ៏ធំរបស់បញ្ញាសិប្បនិមិត្ត (AI) ក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង និងសូម្បីតែក្នុងអភិបាលកិច្ច។ បញ្ហាសន្តិសុខឆ្លងដែន និងភាពតានតឹងជុំវិញជម្លោះទឹកដីសុទ្ធតែបានរួមចំណែកធ្វើឱ្យមានការភ័យខ្លាចកាន់តែខ្លាំងឡើងអំពីការធ្វើអាវុធនុយក្লេអ៊ែរនៃបញ្ញាសិប្បនិមិត្ត (AI) និងការធ្វើសមាហរណកម្មរបស់ខ្លួនចូលទៅក្នុងប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS) ដែលរួមចំណែកដល់ឈ្មោះក្រៅផ្លូវការរបស់ខ្លួនគឺ" មនុស្សយន្តពិឃាដ" ។

មានបណ្តាញអង្គការសង្គមស៊ីវិលដែលកំពុងលេចធ្លោមួយ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលកំពុងធ្វើការយ៉ាងសកម្មលើកង្វល់ទាំងនេះ។ កិច្ចប្រជុំសង្គមស៊ីវិលអាស៊ីអាគ្នេយ៍មួយត្រូវបានរៀបចំឡើងដោយស្ថាប័នអហិង្សាអន្តរជាតិអាស៊ីអាគ្នេយ៍ (NISEA) នៅទីក្រុងបាងកក ប្រទេសថៃ នាខែកក្កដា ឆ្នាំ២០១៩។ ចាប់តាំងពីពេលនោះមក យុទ្ធនាការនៅតាមប្រទេសជាច្រើនត្រូវបានរៀបចំឡើងនៅក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន និងថៃ។ ក្រៅពីការធានាឲ្យបានថាការគ្រប់គ្រងពីមនុស្សដែលមានអត្ថន័យលើប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS) ត្រូវបានរក្សាគោលការណ៍សំខាន់មួយដែលត្រូវបានព្រមព្រៀងគ្នា នៅក្នុងបណ្តាញក្រៅផ្លូវការ នៃអង្គការសង្គមស៊ីវិលអាស៊ី គឺថាឧបករណ៍អន្តរជាតិថ្មីស្តីពីប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS) ត្រូវបានគិតគូរល្អិតល្អន់ពីសំណាក់សម្ព័ន្ធមិត្តនៅកម្រិតអន្តរជាតិ។ អង្គការសង្គមស៊ីវិលមានការព្រួយបារម្ភជាចម្បងអំពីការប្រើប្រាស់បញ្ញាសិប្បនិមិត្ត (AI)នៅក្នុងប្រព័ន្ធអាវុធស្វយ័តគ្រោះថ្នាក់ (LAWS) និងមិនមែនការអភិវឌ្ឍ និងការប្រើប្រាស់បញ្ញាសិប្ប និមិត្ត(AI) នៅក្នុងវិស័យពាណិជ្ជកម្មនោះ■ ។

Nonviolence International, an NGO in Special Consultative Status with the Economic and Social Council (ECOSOC) of the United Nations since 2005, has been working on peacebuilding, conflict transformation, humanitarian disarmament, & peace processes.

+63 2 7966 5090

nonviolenceasia

nonviolenceasia@gmail.com

NONVIOLENCE INTERNATIONAL ASIA